ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

**សារលិខិតអបអរសាទរ**

**ខួបលើកទី ៣៧ នៃការចូលកាន់តំណែងជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយឥតឧបមា និងសូមអបអរសាទរក្រៃលែងចំពោះថ្ងៃទី១៤ ខែមករា គឺជាខួបលើកទី៣៧ឆ្នាំ នៃការចូលកាន់តំណែងជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** ក្នុងរយៈពេល ៣៧ ឆ្នាំកន្លងមកនេះ បានធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ប្រទេសជាតិមានកិត្តិនាម និងល្បីរន្ទឺលើឆាកអន្តរជាតិរហូតដល់បច្ចុប្បន្ន។

ក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ យើងខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ស្មោះស្ម័គ្រចំពោះគំរូវីរភាពនិងការដឹកនាំដ៏ឆ្នើម និងជាប្រវត្តិសាស្ត្រប្រកបដោយជោគជ័យក្នុងការរំដោះប្រទេសជាតិស្វែងរកសន្តិភាព បង្រួបបង្រួមជាតិ កសាងនិងអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើនជាលំដាប់ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏វិសេសវិសាលជាបន្តបន្ទាប់ដោយរក្សាបាននូវសុខសន្តិភាព អធិបតេយ្យភាពបូរណភាពទឹកដីដ៏រឹងមាំ មានការឯកភាពជាតិ ស្ថិរភាពជាតិ និងការរីកចម្រើនជឿនលឿនទៅមុខៗ។ ពិសេសជាងនេះ ជោគជ័យថ្មីមួយទៀតក្នុងពេលថ្មីៗនេះ គឺផ្លែផ្កាដែលលេចចេញពីការខិតខំប្រឹងប្រែងរបស់ **សម្តេចតេជោ** តាមរយៈជំនួបជាមួយនាយឧត្តមសេនីយ៍ **មីន អោងឡាំង** មេដឹកនាំនៃប្រទេសភូមា។

យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ថ្ងៃ អង្គារ ៩ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**